# អនុសាសន៍អំពីសិទ្ធិស្មើភាពគ្នារបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលយក នៅក្នុងរបាយការណ៍ពិនិត្យឡើងវិញជាសកលតាមកាលកំណត់ ( យូ.ភី.អ / UPR ) ជុំទី៤

ក្នុងអំឡុងពេល ការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ ( យូ.ភី.អ / UPR ) ជុំទី៤ របស់ប្រទេសកម្ពុជាក្នុងឆ្នាំ២០២៤ រាជរដ្ឋាភិបាលកម្ពុជាបានទទួលយកអនុសាសន៍ទាំង១២ ដែលផ្តោតទៅលើការបន្តនូវវឌ្ឍនភាពនៃសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ( សូជីអេសស៊ី / SOGIESC ) ឬសិទ្ធិស្មើភាពគ្នារបស់អ្នកស្រឡាញ់ភេទដូចគ្នា ( LGBTIQ+) ។ ការទទួលយកអនុសាសន៍ យូ.ភី.អ / UPR ជុំទី៤ នេះ ផ្តោតទៅលើអាទិភាពសំខាន់ៗចំនួនបីគឺ៖

- → ការបន្តនូវវឌ្ឍនភាពឆ្ពោះទៅរកការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា
- → បង្កើតឱ្យមានច្បាប់ទទួលស្គាល់អត្តសញ្ញាណយេនឌ័រ ដែលកំណត់ដោយបុគ្គល ជាអ្នកប្តូរយេនឌ័រ និងបុគ្គលដែលមានអត្តសញ្ញាណយេនឌ័រចម្រុះ
- → ការទទួលបានសមភាពពេញលេញសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា និងអនុវត្តនូវវិធានការការពារប្រកបដោយប្រសិទ្ធិភាពចំពោះការរើសអើងផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ( សូជីអេសស៊ី / SOGIESC)

*អនុសាសន៍ទាំងអស់នេះ គឺបន្តនូវវឌ្ឍនភាពនៃសិទ្ធិស្មើភាពគ្នារបស់អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា ដែលបានផ្តល់ឱ្យដោយរដ្ឋ ឬប្រទេស ចំនួន១០ នៃសមាជិកអង្គការសហប្រជាជាតិរួមមាន៖ ម៉ិចស៊ិក ហូឡង់ ស៊ុយអែត ចក្រភពអង់គ្លេស អ៊ុយរូហ្គាយ អូស្ត្រាលី កាណាដា បារាំង អាល្លឺម៉ង់ និងអ៉ីស្លង់។*

| អនុសាសន៍អំពីសិទ្ធិស្មើភាពគ្នារបស់អ្នកស្រឡាញ់ភេទដូចគ្នា ( សូជីអេសស៊ី/ SOGIESC ) ដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលយក | | |
|---|---|---|
| | *អនុសាសន៍ជាក់លាក់អំពីសិទ្ធិស្មើភាពគ្នារបស់អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI+ )* | *អាទិភាពសំខាន់ៗ* |
| 1 | បន្តវឌ្ឍនភាពឆ្ពោះទៅរកសមភាពពេញលេញសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI+ ) រួមទាំងការទទួលស្គាល់ស្របច្បាប់ចំពោះអាពាហ៍ពិពាហ៍គូស្រករភេទដូចគ្នា ( អូស្ត្រាលី, ១៣៩.២៦៤ ) | បន្តវឌ្ឍនភាពឆ្ពោះទៅរកការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា និងសមភាពពេញលេញសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា |
| 2 | បន្តវឌ្ឍនភាពឆ្ពោះទៅរកការអនុម័តនូវវិសោធនកម្មច្បាប់ ក្នុងការទទួលស្គាល់សមភាពអាពាហ៍ពិពាហ៍គូស្រករភេទដូចគ្នា ដើម្បីធានានូវសមភាព និងបរិយាបន្នសង្គមពេញលេញសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា ( LGBTQI+ ) នៅកម្ពុជា ( ព្រះរាជាណាចក្រហូឡង់, ១៣៩.២៦៥ ) | បន្តវឌ្ឍនភាពឆ្ពោះទៅរកការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា |
| 3 | បន្តវឌ្ឍនភាពឆ្ពោះទៅរកការទទួលស្គាល់ស្របច្បាប់ចំពោះអាពាហ៍ពិពាហ៍គូស្រករភេទដូចគ្នា ( កាណាដា, ១៣៩.២៦៣ ) | បន្តវឌ្ឍនភាពឆ្ពោះទៅរកការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា |
| 4 | បន្តវឌ្ឍនភាពឆ្ពោះទៅរកការអនុម័តនូវវិសោធនកម្មច្បាប់ ក្នុងការទទួលស្គាល់សមភាពអាពាហ៍ពិពាហ៍គូស្រករភេទដូចគ្នា ដើម្បីឱ្យមានសមភាពចំពោះមុខច្បាប់ ដែលនឹងសម្រេចបានការមិនរើសអើង សមភាព និងបរិយាប័ន្នសង្គមពេញលេញសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា ( LGBTQI+ ) នៅកម្ពុជា ( អាល្លឺម៉ង់, ១៣៩.២៦៦ ) | បន្តវឌ្ឍនភាពឆ្ពោះទៅរកការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា |
| 5 | រៀបចំឱ្យមានច្បាប់ និងធ្វើវិសោធនកម្មច្បាប់ជាធរមាន ដើម្បីទទួលស្គាល់សមភាពអាពាហ៍ពិពាហ៍គូស្រករភេទដូចគ្នា ( ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង, ១៣៩.២៦៧ ) | បន្តវឌ្ឍនភាពឆ្ពោះទៅរកការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា |
| 6 | ទទួលស្គាល់អាពាហ៍ពិពាហ៍គូស្រករភេទដូចគ្នាឱ្យមានសមភាពចំពោះមុខច្បាប់ ( អ៉ីស្លង់, ១៣៩.២៦៨ ) | បន្តវឌ្ឍនភាពឆ្ពោះទៅរកការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា |
| 7 | ពន្លឿនការរៀបចំក្របខណ្ឌច្បាប់ ដែលទទួលស្គាល់ស្របច្បាប់ចំពោះអត្តសញ្ញាណយេនឌ័រកំណត់ដោយសាមីខ្លួន និងអាពាហ៍ពិពាហ៍ស្មើភាពគ្នារវាងគូស្រករភេទដូចគ្នា ( ម៉ិចស៊ិក, ១៣៩.២៦៩ ) | បន្តវឌ្ឍនភាពឆ្ពោះទៅរកការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា និងបង្កើតឱ្យមានច្បាប់ទទួលស្គាល់អត្តសញ្ញាណយេនឌ័រ ដែលកំណត់ដោយបុគ្គល |
| 8 | អនុម័ត និងអនុវត្តនីតិវិធីរដ្ឋបាលប្រកបដោយតម្លាភាព ដើម្បីទទួលស្គាល់តាមផ្លូវច្បាប់ចំពោះអត្តសញ្ញាណយេនឌ័រកំណត់ដោយសាមីខ្លួន ( អ៉ីស្លង់, ១៣៩. ២៧០ ) | បង្កើតឱ្យមានច្បាប់ទទួលស្គាល់អត្តសញ្ញាណយេនឌ័រ ដែលកំណត់ដោយបុគ្គល |

| | | |
|---|---|---|
| 9 | ធានាបរិយាបន្ន និងកិច្ចការពារប្រកបដោយប្រសិទ្ធភាពចំពោះអ្នកដែលមាននិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងលក្ខណៈភេទចម្រុះ(សូជីអេសស៊ី / SOGIESC) នៅក្នុងច្បាប់ និងគោលនយោបាយពាក់ព័ន្ធ (អ៊ីស្លង់, ១៣៩. ២៦១) | បន្តវឌ្ឍនភាពអនុវត្តនូវវិធានការការពារប្រកបដោយប្រសិទ្ធភាពចំពោះការរើសអើងផ្អែកទៅលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ (សូជីអេសស៊ី / SOGIESC) |
| 10 | ធានាបរិយាបន្ន និងកិច្ចការពារប្រកបដោយប្រសិទ្ធភាពសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI+) នៅក្នុងច្បាប់ និងគោលនយោបាយពាក់ព័ន្ធ ដើម្បីប្រឆាំងការរើសអើង និងអំពើហិង្សាផ្អែកលើយេនឌ័រ ទាំងនៅសាលារៀន វិស័យការងារ វិស័យថែទាំសុខភាព និងទីសាធារណៈ (ស៊ុយអែត, ១៣៩.២៦០) | បន្តវឌ្ឍនភាពអនុវត្តនូវវិធានការការពារប្រកបដោយប្រសិទ្ធភាពពីការរើសអើងផ្អែកទៅលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ (សូជីអេសស៊ី / SOGIESC) |
| 11 | បន្តកិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅរកសិទ្ធិស្មើភាពគ្នាសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI+) (បារាំង, ១៣៩.២៥៩) | បន្តវឌ្ឍនភាពសិទ្ធិស្មើភាពគ្នាសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI+) |
| 12 | អនុម័តវិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីប្រឆាំង និងដាក់ទោសទណ្ឌចំពោះការរើសអើង និងអំពើហិង្សាផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ (អ៊ុយរូហ្គាយ,១៣៩.២៦២) | បន្តវឌ្ឍនភាពអនុវត្តនូវវិធានការការពារប្រកបដោយប្រសិទ្ធភាពពីការរើសអើង ផ្អែកទៅលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ (សូជីអេសស៊ី / SOGIESC) |

*ក្រុមប្រឹក្សាសិទ្ធិមនុស្ស សម័យប្រជុំលើកទី៥៧, របាយការណ៍របស់ក្រុមការងារស្តីពី ការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ របស់កម្ពុជា*

រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចទទួលយកអនុសាសន៍យូ.ភី.អ (UPR) ជុំទី៤ អំពីសិទ្ធិស្មើភាពគ្នារបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ដែលសបញ្ជាក់ពីភាពជាវិជ្ជមានដ៏មានសារៈសំខាន់របស់កម្ពុជា ក្នុងការបន្តការប្តេជ្ញាចិត្តចំពោះវឌ្ឍនភាពនៃស្ថានភាពសិទ្ធិស្មើភាពគ្នារបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា។ ដំណឹងដ៏វិសេសវិសាលនេះ បានជំរុញទឹកចិត្តដល់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាយើង ឱ្យមានសេចក្តីសង្ឃឹម និងភាពជឿជាក់ថាយើងនឹងសម្រេចបាននូវសមភាពពេញលេញសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងពេលឆាប់ៗខាងមុខនេះ នៅក្នុងសង្គមកម្ពុជាប្រកបដោយបរិយាប័ន្ន និងភាពសុខដុម។ យើងនឹងបន្តខិតខំប្រឹងប្រែងធ្វើការរួមគ្នាជាមួយភាគីពាក់ព័ន្ធ តាមរយៈកិច្ចសន្ទនានិងកិច្ចសហប្រតិបត្តិការ ក្នុងដំណើរឆ្ពោះទៅរកវឌ្ឍនភាពនៃសិទ្ធិស្មើគ្នាសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា ជាពិសេសសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា ដែលជាតម្រូវការអាទិភាពរបស់សហគមន៍យើង ក្នុងការធានាបាននូវការមិនរើសអើង សមភាព បរិយាបន្ន និងភាពសុខដុមក្នុងសង្គម ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព «មិនទុកនរណាម្នាក់ចោល»។

*សម្រាប់ព័ត៏មានបន្ថែមសូមមើលរបាយការណ៍ត្រួតពិនិត្យជាសកលតាមកាលកំណត់ (យូ.ភី.អ) តាមរយៈគេហទំព័រ* https://www.ohchr.org/en/hr-bodies/upr/kh-index. របាយការណ៍រួមរបស់អង្គការសង្គមស៊ីវិល នៃយន្តការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ (យូ.ភី.អ / UPR) ជុំទី៤ ស្តីពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី / SOGIESC) និងសិទ្ធិសុខភាពផ្លូវភេទ និងបន្តពូជ (អេស.អ.អេជ.អ / SRHR) របស់កម្ពុជា https://rockcambodia.org/4th-cycle-upr-sogiesc-srhr-cambodia/